**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-May-2014, 14:55
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្ម ដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**ជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

[០០២/១៩-០៩-២០០៧-អវតក/អជសដ]

កញ្ញា អ៊ុំច ស្រីផាត

កញ្ញា សេង លីណា

កញ្ញា Cécile ROUBEIX

**មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីខាងការពារក្ដី លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានផ្តល់ "*ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់* "។[1] អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគី ផ្តល់ព័ត៌មានបន្ថែមទៅលើអញ្ញត្រកម្មពីរ ដែលក្រុមមេធាវីការពារក្តី លោក អៀង សារី បានលើកឡើងកាលពីពេលមុន ដូចជា ៖

- អញ្ញត្រកម្មទាក់ទិននឹងអាជ្ញាយុកាលនៃបទល្មើសនៃការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ
- អញ្ញត្រកម្មស្តីពីយុត្តាធិការនៃអង្គជំនុំជម្រះលើការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។[2]

២. អង្គជំនុំជម្រះបានបញ្ជាក់ថា "*ជាបឋម ភាគីត្រូវបញ្ជាក់ប្រាប់អង្គជំនុំជម្រះថា តើខ្លួនយល់ស្របទៅនឹងពីអញ្ញត្រកម្មដែលលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី ដែរឬទេ។ បើសិនយល់ស្រប ភាគីត្រូវបញ្ជាក់ពីជំហរនានារបស់ខ្លួនលើបញ្ហានេះ*"។[3]

៣. ថ្ងៃនេះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ("មេធាវីការពារក្តី") សូមជូនដំណឹងទៅអង្គជំនុំជម្រះថា មេធាវីការពារក្តីយើងខ្ញុំយល់ស្របតាមអញ្ញត្រកម្មទាំងពីរ ហើយសូមបញ្ជាក់ពីជំហររបស់ខ្លួនថា ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវផុតអាជ្ញាយុកាលទៅហើយ (I) ហើយ អង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការជំនុំជម្រះលើការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះឡើយ (II)។

---

[1] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ **E306**

[2] ដូចគ្នា កថាខណ្ឌទី៥

[3] ដូចគ្នា។ ថ្ងៃដាក់ឯកសារដែលបានកំណត់កាលពីដំបូងត្រឹមថ្ងៃទី១៦ ឧសភា ២០១៤ ត្រូវបានលើកទៅត្រឹមថ្ងៃទី២៦ ឧសភា ២០១៤ (សូមអានសេចក្តីជូនដំណឹងពីការដាក់ឯកសារ - *Fw: Notice of deficient Filing* របស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ឧសភា ២០១៤ ម៉ោង ១៧ម៉០១។

## I. អាជ្ញាយុកាលនៃបទល្មើសការរំលោភបំពានផ្លូវច្បាប់លើអនុសញ្ញាក្រុងហ្សឺណែវ

## ក. រំឭកនីតិវិធី

៤. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី លោក អៀង សារី បានដាក់សេចក្តីសន្និដ្ឋាន ពាក់ព័ន្ធនឹងអវត្តមានយុត្តាធិការនៃអង្គជំនុំជម្រះ លើការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ដោយហេតុថា អាជ្ញាយុកាលនៃអនុសញ្ញានេះបានផុតរលត់តាំងពីឆ្នាំ១៩៨៩ ម្ល៉េះ។[4]

៥. ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានផ្តល់សម្អាងហេតុនៃដីកាសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី លោក អៀង សារី ប្រឆាំងទៅនឹងដីកាដំណោះស្រាយ។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា *"អនុសញ្ញាទីក្រុងហ្សឺណែវដែលជាច្បាប់អាចអនុវត្តបានក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ចែងថា ឧក្រិដ្ឋកម្មសង្គ្រាមពុំមានអាជ្ញាយុកាលនោះទេ ដែលបង្ហាញថាពុំមានអាជ្ញាយុកាលអាចអនុវត្តបានទេ"* ។[5]

៦. ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី លោក អៀង សារី បានស្នើសុំដល់អង្គជំនុំជម្រះ ដើម្បីដាក់សារណាបន្ថែម ដើម្បីពន្យល់ពីការវិភាគមិនត្រឹមត្រូវនៃអង្គបុរេជំនុំជម្រះ។[6]

៧. ថ្ងៃទី២៨ និងទី២៩ ខែមិថុនា ឆ្នាំ២០១១ នៅក្នុងសវនាការបឋម ការចោទជាបញ្ហានេះជាកម្មវត្ថុនៃការពិភាក្សាដេញដោល រវាងក្រុមមេធាវីការពារក្តី លោក អៀង សារី សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។[7]

---

[4] អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ) ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ **E43** (« **E43** »)។

[5] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ **D427/1/30** កថាខណ្ឌទី ៧៣។

[6] ការបង្ហាញរបស់ អៀង សារី លើផ្នែកនៃសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលតម្រូវឱ្យមានសារណាបន្ថែមទាក់ទងនឹងការអនុវត្តនៅ អវតក នូវឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ **E83** កថាខណ្ឌទី៦។

[7] របៀបវារៈសម្រាប់សវនាការបឋម ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១១ **E86/1** កថាខណ្ឌទី៤។ ប្រតិចារឹកសវនាការនៃ (« T. ») ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១១ **E1/5.1** ទំព័រទី៨៦ ដល់ទី១២២ ។ ») T. ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០១១ **E1/6.1** ទំព័រទី៣ ដល់ទី១៨ ។

៨. ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានសម្រេចបំបែកដំណើរការនីតិវិធី នៅក្នុងសំណុំរឿង ០០២ និងលើកពេលការពិនិត្យលើបញ្ហាទាំងនេះទៅសវនាការក្រោយៗទៀត។[8]

## ខ. សម្អាងហេតុ

៩. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន យល់ស្របតាមទាំងស្រុងនូវអំណះអំណាងរបស់ក្រុមមេធាវីការពារក្តី លោក អៀង សារី គឺជាអំណះអំណាងដែលយើងខ្ញុំយកជាយោងដោយមិនបានពង្រីកសេចក្តី លើកលែងតែអំណះអំណាងដែលទាញចេញពីច្បាប់បារាំង។

១០. នៅឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី លោក អៀង សារី បានលើកយកឧទាហរណ៍ពីក្នុងច្បាប់បារាំង ដែលបានប្រើជាគម្រូនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ហើយដែលបំបែកពីគ្នារវាងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះមិនមានអាជ្ញាយុកាលទេ ដែលវាខុសពីឧក្រិដ្ឋកម្មសង្គ្រាម។ ក្រុមមេធាវីការពារក្តី លោក អៀង សារី ក៏បានស្រង់យុត្តិសាស្ត្ររឿងក្តី *Barbie* នៅឆ្នាំ ១៩៨៥។[9]

១១. នៅឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះឲ្យទាត់ចោលចំណុចនោះដោយសម្អាងថា យុត្តិសាស្ត្រក្នុងរឿងក្តី *Barbie* បានផ្អែកលើច្បាប់បារាំងនៅឆ្នាំ ១៩៦៤ ដែល *"បានលើកលែងចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"* ហើយថា ការបំបែកគ្នារវាងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺ "*មិនមានអត្ថន័យទេ*"។[10]

១២. តែនៅឆ្នាំ២០១០ អ្នកតាក់តែងច្បាប់បារាំងដែលបានសម្របច្បាប់ព្រហ្មទណ្ឌបារាំងទៅតាមគំរូតុលាការព្រហ្មទណ្ឌអន្តរជាតិ ("CPI") នៅតែរក្សាការញែកដាច់ពីគ្នា រវាងឧក្រិដ្ឋកម្ម

---

[8] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១១ **E124**។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ **E284** ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ កំណត់ជើងទំព័រលេខ ២១២, ២៧១ និង ២៧៥។

[9] **E43** កថាខណ្ឌទី៨។ (« T. ») ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១១ **E1/5.1** ទំព័រ ១០១ បន្ទាត់ទី៦ដល់ទី១២។

[10] (« T. ») ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១១ **E1/5.1** ទំព័រ ១២០ បន្ទាត់ទី២១ ដល់ទំព័រទី១២១ បន្ទាត់ទី១១ ។

សង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយបានបន្ថែមថិរវេលាកំណត់អាជ្ញាយុកាលនៃឧក្រិដ្ឋកម្មសង្គ្រាមទៀតផង។[11] ក្រុមប្រឹក្សាធម្មនុញ្ញបានចាត់ទុកថា ទង្វើបែបនេះ អ្នកតាក់តែងច្បាប់មិនបានមើលរំលងគោលការណ៍នីត្យានុកូលភាពនោះទេ។[12]

១៣. ទោះជាយ៉ាងណាក្តី ក្រុមមេធាវីការពារក្តី សូមទទូចទៅលើចំណុចដែលថា ផ្ទុយពីការអះអាងរបស់អង្គបុរេជំនុំជម្រះ អនុសញ្ញាក្រុងហ្សឺណែវមិនមានចែងនូវបទបញ្ញត្តិណាមួយពាក់ព័ន្ធទៅនឹងការពុំមានអាជ្ញាយុកាលនៃបទល្មើសនេះឡើយ។ ទន្ទឹមនឹងនេះ ការពុំមានអាជ្ញាយុកាលនេះ មិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ។ បើតាមច្បាប់អនុវត្តន៍នៅប្រទេសកម្ពុជា ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ត្រូវបានផុតរលត់យ៉ាងយូរត្រឹមឆ្នាំ១៩៨៩ មកម្ល៉េះ។ ដូច្នេះ អង្គជំនុំជម្រះ មិនមានយុត្តាធិការក្នុងការជម្រះរឿងនេះ នៅពេលបច្ចុប្បន្ននេះឡើយ។

## II. អង្គជំនុំជម្រះមិនមានយុត្តាធិការលើការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១៤. ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី លោក អៀង សារី បានលើកឡើងថា *"ត្រូវតែលុបចោល"* ដីកាដំណោះស្រាយ ពីកថាខណ្ឌ១៣៩៧ ដល់ ១៤០១ ដែលទាក់ទិននឹងការនិរទេសជនជាតិវៀតណាម នៅខេត្តព្រៃវែង ស្វាយរៀង និងសហករណ៍ស្រុកត្រាំកក់។ ក្រុមមេធាវីបានលើកឡើងដោយមានសម្អាងហេតុ យ៉ាងត្រឹមត្រូវ ថា វិធានផ្ទៃក្នុងមិនអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបសួរលើអង្គហេតុទាំងនោះ ដែលជាអង្គហេតុមិនមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរណាមួយរបស់សហព្រះរាជអាជ្ញាឡើយ។[13]

១៥. ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានអះអាងថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមាន *"មូលដ្ឋានគ្រប់គ្រាន់មួយ"* ដែលអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត

---

[11] ច្បាប់លេខ 2010-930 ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១០ ស្តីពីការសម្របសម្រួលច្បាប់ព្រហ្មទណ្ឌនៅក្នុងស្ថាប័ន CPI មាត្រា៧។

[12] ដីកាសម្រេចលេខ 2010-612 DC នៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ ២០១០ មូលបទ ៧។

[13] ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ **E58** កថាខណ្ឌទី១១

បើកការស៊ើបសួរលើអង្គហេតុទាំងនោះ។[14] សហព្រះរាជអាជ្ញាបានអះអាងថា សហចៅក្រមស៊ើបអង្កេតទទួលបានសិទ្ធិស៊ើបអង្កេត លើការនិទេស[15] ការជម្លៀសប្រជាជនដំណាក់កាលទីបី[16] និងការដាក់គោលដៅលើជនជាតិវៀតណាម។[17]

១៦. ក៏ប៉ុន្តែ កថាខណ្ឌនានាក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ ទាក់ទងតែការជម្លៀសដំណាក់កាលទី១ ទី២ និងទី៣ តែប៉ុណ្ណោះ។ សកម្មភាពនេះមិនពាក់ព័ន្ធនឹងការនិរទេសប្រជាជន ទៅប្រទេសវៀតណាមនោះឡើយ ហើយវាសំដៅប្រជាជនគ្រប់គ្នាទាំងអស់ មិនមានគោលដៅតែចំពោះជនជាតិវៀតណាមជាពិសេសនោះឡើយ។ ដូច្នេះ ការជម្លៀសលើកទីបីនៅខេត្តព្រៃវែង និងស្វាយរៀង មិនចំពោះតែប្រជាជនវៀតណាមជាពិសេសនោះឡើយ (តែវាពាក់ព័ន្ធនឹងប្រជាជនទាំងអស់គ្នា) ហើយក៏មិនពាក់ព័ន្ធនឹងការនិរទេសទៅកាន់ប្រទេសវៀតណាមនោះក៏ទេដែរ។ ចុងបញ្ចប់ ពិតមែនតែសហព្រះរាជអាជ្ញាបានលើកឡើង ពីវត្តមាននៃនយោបាយកំណត់គោលដៅចំពោះជនជាតិវៀតណាមមែន តែនយោបាយនេះសំដៅលើការកម្ទេច ជាពិសេសដោយការសម្លាប់តែប៉ុណ្ណោះ។[18] ដូច្នេះ នយោបាយកំណត់សំដៅប្រជាជនវៀតណាមនេះមិនពាក់ព័ន្ធនឹងការនិរទេសនោះទេ។

១៧. ម៉្យាងទៀត គេគប្បីគូសបញ្ជាក់ថា សហព្រះរាជអាជ្ញាមិនបានឆ្លើយតបនឹងអំណះអំណាងរបស់ក្រុមមេធាវីការពារក្តី លោក អៀង សារី ឡើយ ពាក់ព័ន្ធនឹងសហករណ៍ស្រុកត្រាំកក់។

---

[14] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១១ **E58/1** កថាខណ្ឌទី២៩

[15] ដូចខាងលើ កំណត់ជើងទំព័រលេខ ៦៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ **D3** កថាខណ្ឌទី១២២ គ)

[16] ដូចខាងលើ កំណត់ជើងទំព័រលេខ ៦៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ **D3** កថាខណ្ឌទី៤២

[17] ដូចខាងលើ កំណត់ជើងទំព័រលេខ ៦៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ **D3** កថាខណ្ឌទី៦៩

[18] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ **D3** កថាខណ្ឌទី៦៩៖ *"ប.ក.ក ធ្វើសកម្មភាពសំដៅកម្ទេចរូបកាយប្រជាជនវៀតណាមទាំងស្រុង នៅខេត្តព្រៃវែង ដោយការសម្លាប់។ ផែនការនេះមួយផ្នែកគឺ [...] សម្លាប់ទាំងម្តាយទាំងកូន បើសិនជាមាន ប្រសិនបើម្តាយមានសញ្ជាតិវៀតណាម"*។

១៨. ការព្យាយាមបកស្រាយបង្ហាញរបស់សហព្រះរាជអាជ្ញានេះ មិនត្រឹមត្រូវទៅនឹងការវិភាគកថាខណ្ឌនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះឡើយ។ ដូច្នេះ មេធាវីការពារក្តីលោក ខៀវ សំផន យល់ស្របតាមសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី លោក អៀង សារី ដែលថា សហចៅក្រមស៊ើបអង្កេតមិនមានអំនាចក្នុងការស៊ើបអង្កេតទៅលើអង្គហេតុទាក់ទងទៅនឹងការនិរទេសជនជាតិវៀតណាម នៅខេត្តព្រៃវែង ស្វាយរៀង និងនៅសហករណ៍ស្រុកតាំកក់នោះឡើយ។

១៩. ពីព្រោះថា ពាក្យពេចន៍នៅក្នុងវិធានផ្ទៃក្នុង មិនបាននាំឲ្យមានការសង្ស័យបន្តិចសោះឡើយទៅលើវិសាលភាពនៃការទទួលបណ្តឹងនៃសហចៅក្រមស៊ើបអង្កេត *"ដែលត្រូវស៊ើបអង្កេតលើអង្គហេតុដែលបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"។*[19] ដូចគ្នានេះដែរ នៅក្នុងច្បាប់កម្ពុជា[20] និងច្បាប់បារាំង[21]។ ម៉្យាងទៀតយុត្តិសាស្ត្របារាំងក៏បានអះអាងផងដែរពីភាពរឹងបន្តឹងនៃវិធាននេះជាច្រើនលើកច្រើនសា។[22]

២០. ដោយសារតែ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងយ៉ាងត្រឹមត្រូវអំពីបទចោទប្រកាន់លើការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយដូច្នេះអង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការជំនុំជម្រះលើចំណុចនេះឡើយ។ នេះជាគោលការណ៍ច្បាប់ដ៏សំខាន់បំផុត ដែលមិនអាចលើកលែងបានឡើយ លើកលែងតែគេធ្វើមិនដឹងមិនឮចំពោះបទបញ្ញត្តិដែលចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង និងច្បាប់កម្ពុជា ដែលនោះជា

---

[19] វិធានផ្ទក្នុង វិធាន ៥៥.២។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥ ៖ *"ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្របស៊ើបសួរត្រូវស៊ើបសួរតែពីអង្គហេតុនោះប៉ុណ្ណោះ"។*

[21] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៨០។

[22] ជាឧទាហរណ៍ សូមអាន តុលាការកំពូល-ផ្នែកបទឧក្រិដ្ឋ ព្រឹត្តិបត្តិផ្នែកបទឧក្រិដ្ឋ លេខ ១៨០ ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៣ ។ តុលាការ-ផ្នែកបទឧក្រិដ្ឋ ព្រឹត្តិបត្តិផ្នែកបទឧក្រិដ្ឋ លេខ ២៤០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៤ ៖ *"... មាត្រា ៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហាមចៅក្របស៊ើបសួរមិនឲ្យស៊ើបសួរលើអង្គហេតុដែលមិនទទួលបានបណ្តឹងស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីរដ្ឋអាជ្ញានៃសាធារណរដ្ឋបារាំងនោះឡើយ..."*។ តុលាការកំពូល-ផ្នែកបទឧក្រិដ្ឋ ព្រឹត្តិបត្តិផ្នែកបទឧក្រិដ្ឋ លេខ ៦០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៨៦ ៖ *"...អំណាចដែលប្រគល់ជូនចៅក្រមស៊ើបសួរ [...] ហើយដោយអនុលោមតាមច្បាប់ អាចឲ្យចៅក្រមស៊ើបសួរដែលមានអត្ថប្រយោជន៍ដល់ការស្វែងរកការពិតគឺកម្រិតតែត្រឹមអង្គហេតុណាដែលទទួលបានបណ្តឹង..."*។

ការរំលោភយ៉ាងច្បាស់ក្រឡែត ទៅលើសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌។

២១. **អាស្រ័យហេតុនេះ** មេធាវីការពារក្តី លោក ខៀវ សំផន សូមអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ប្រកាស** និង**វិនិច្ឆ័យ**ថា ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវបានផុតអាជ្ញាយុកាលទៅហើយ និងថា អង្គជំនុំជម្រះលែងមានយុត្តាធិការលើបញ្ហានេះហើយ
- **ប្រកាស** និង**វិនិច្ឆ័យ**ថា អង្គជំនុំជម្រះមិនមានយុត្តាធិការលើការកំណត់ការនិរទេសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |